**Middle East respiratory syndrome coronavirus (MERS-CoV)**
Fact sheet N°401June 2015

## Key facts

- Middle East respiratory syndrome (MERS) is a viral respiratory disease caused by a novel coronavirus (MERS-CoV) that was first identified in Saudi Arabia in 2012.
- Coronaviruses are a large family of viruses that can cause diseases ranging from the common cold to Severe Acute Respiratory Syndrome (SARS).
- Typical MERS symptoms include fever, cough and shortness of breath. Pneumonia is common, but not always present. Gastrointestinal symptoms, including diarrhoea, have also been reported.
- Approximately 36% of reported patients with MERS have died.
- Although the majority of human cases of MERS have been attributed to human-to-human infections, camels are likely to be a major reservoir host for MERS-CoV and an animal source of MERS infection in humans. However, the exact role of camels in transmission of the virus and the exact route(s) of transmission are unknown.
- The virus does not seem to pass easily from person to person unless there is close contact, such as occurs when providing unprotected care to a patient.

## Symptoms

The clinical spectrum of MERS-CoV infection ranges from no symptoms (asymptomatic) or mild respiratory symptoms to severe acute respiratory disease and death. A typical presentation of MERS-CoV disease is fever, cough and shortness of breath. Pneumonia is a common finding, but not always present. Gastrointestinal symptoms, including diarrhoea, have also been reported. Severe illness can cause respiratory failure that requires mechanical ventilation and support in an intensive care unit. Approximately 36% of reported patients with MERS-CoV have died. The virus appears to cause more severe disease in older people, people with weakened immune systems, and those with chronic diseases such as cancer, chronic lung disease and diabetes.

## Source of the virus

MERS-CoV is a zoonotic virus that is transmitted from animals to humans. The origins of the virus are not fully understood but, according to the analysis of different virus genomes, it is believed that it originated in bats and was transmitted to camels sometime in the distant past

## Transmission

Non-human to human transmission: The route of transmission from animals to humans is not fully understood, but camels are likely to be a major reservoir host for MERS-CoV and an animal source of infection in humans. Strains of MERS-CoV that are identical to human strains have been isolated from camels in several countries, including Egypt, Oman, Qatar, and Saudi Arabia.

Human-to-human transmission: The virus does not appear to pass easily from person to person unless there is close contact, such as providing unprotected care to an infected

patient. There have been clusters of cases in healthcare facilities, where human-to-human transmission appears to be more probable, especially when infection prevention and control practices are inadequate. Thus far, no sustained community transmission has been documented.

The virus appears to be circulating throughout the Arabian Peninsula, primarily in Saudi Arabia, where the majority of cases (>85%) have been reported since 2012. Several cases have been reported outside the Middle East. Most of these infections are believed to have been acquired in the Middle East, and then exported outside the region. The ongoing outbreak in the Republic of Korea is the largest outbreak outside of the Middle East, and while concerning, there is no evidence of sustained human to human transmission in the Republic of Korea. For all other exported cases, no secondary or limited secondary transmission has been reported in countries with exported cases.

**Prevention and treatment**

No vaccine or specific treatment is currently available. Treatment is supportive and based on the patient's clinical condition.

As a general precaution, anyone visiting farms, markets, barns, or other places where camels and other animals are present should practice general hygiene measures, including regular hand washing before and after touching animals, and should avoid contact with sick animals.

The consumption of raw or undercooked animal products, including milk and meat, carries a high risk of infection from a variety of organisms that might cause disease in humans. Animal products that are processed appropriately through cooking or pasteurization are safe for consumption, but should also be handled with care to avoid cross contamination with uncooked foods. Camel meat and camel milk are nutritious products that can continue to be consumed after pasteurization, cooking, or other heat treatments.

Until more is understood about MERS-CoV, people with diabetes, renal failure, chronic lung disease, and immunocompromised persons are considered to be at high risk of severe disease from MERS-CoV infection. These people should avoid contact with camels, drinking raw camel milk or camel urine, or eating meat that has not been properly cooked.

**Health-care facilities**

Transmission of the virus has occurred in health-care facilities in several countries, including from patients to health-care providers and between patients in a health care setting before MERS-CoV was diagnosed. It is not always possible to identify patients with MERS-CoV early or without testing because symptoms and other clinical features may be non-specific.

Infection prevention and control measures are critical to prevent the possible spread of MERS-CoV in health-care facilities. Facilities that provide care for patients suspected or confirmed to be infected with MERS-CoV should take appropriate measures to decrease the risk of transmission of the virus from an infected patient to other patients, health-care workers, or visitors. Health-care workers should be educated and trained in infection prevention and control and should refresh these skills regularly.

**Travel**

WHO does not recommend the application of any travel or trade restrictions or entry screening related to MERS-CoV.

**WHO response**

WHO is working with clinicians and scientists in affected countries and internationally to gather and share scientific evidence to better understand the virus and the disease it causes, and to determine outbreak response priorities, treatment strategies, and clinical management approaches. The Organization is also working with countries to develop public health prevention strategies to combat the virus.

Together with affected countries and international technical partners and networks, WHO is coordinating the global health response to MERS, including: the provision of updated information on the situation; conducting risk assessments and joint investigations with national authorities; convening scientific meetings; and developing guidance and training for health authorities and technical health agencies on interim surveillance recommendations, laboratory testing of cases, infection prevention and control, and clinical management.

The Director-General has convened an Emergency Committee under the International Health Regulations (2005) to advise her as to whether this event constitutes a Public Health Emergency of International Concern (PHEIC) and on the public health measures that should be taken. The Committee has met a number of times since the disease was first identified. WHO encourages all Member States to enhance their surveillance for severe acute respiratory infections (SARI) and to carefully review any unusual patterns of SARI or pneumonia cases.

Countries, whether or not MERS cases have been reported in them, should maintain a high level of vigilance, especially those with large numbers of travellers or migrant workers returning from the Middle East. Surveillance should continue to be enhanced in these countries according to WHO guidelines, along with infection prevention and control procedures in health-care facilities. WHO continues to request that Member States report to WHO all confirmed and probable cases of infection with MERS-CoV together with information about their exposure, testing, and clinical course to inform the most effective international preparedness and response.

**ជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ាចម្លងដោយមេរោគកូរ៉ូណាវីរុស**
អត្ថបទការពិតលេខ៤០១ ខែមិថុនា ឆ្នាំ២០១៥

## ការពិតសំខាន់ៗ

- ជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) គឺជាជំងឺផ្លូវដង្ហើមដែលបង្កដោយមេរោគវីរុស បណ្តាលមកពីមេរោគកូរ៉ូណាវីរុសថ្មី (MERS-Cov) ដែលបានរកឃើញដំបូងនៅក្នុងប្រទេសអារាប៊ីសាអូឌីត ក្នុងឆ្នាំ២០១២។
- មេរោគកូរ៉ូណាវីរុស គឺជាគ្រួសារធំមួយដែលអាចបណ្តាលឱ្យមានជំងឺ ចាប់ពីផ្តាសាយធម្មតារហូតដល់ជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SARS)។
- រោគសញ្ញាជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) ជាធម្មតារាប់បញ្ចូលទាំងគ្រុនក្តៅ ក្អក និងដកដង្ហើមខ្លីៗ។ តាមធម្មតាមានជំងឺរលាកសួត ប៉ុន្តែមិនមែនមានជានិច្ចជាកាលនោះទេ។ មានរោគសញ្ញាក្រពះពោះវៀន រាប់បញ្ចូលទាំងជំងឺរាក ក៏ត្រូវបានរាយការណ៍ផងដែរ។
- អ្នកជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) ៣៦%ត្រូវបានរាយការណ៍ថាបានស្លាប់បាត់បង់ជីវិត។
- ទោះបីជាមនុស្សភាគច្រើនមានករណីជំងឺផ្លូវដង្ហើមមជ្ឈឹមបូព៌ា (MERS) ដែលបានឆ្លងពីមនុស្សទៅមនុស្ស សត្វអូដប្រហែលជាប្រភពនាំឱ្យឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) ហើយសត្វគឺជាប្រភពចម្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) មកមនុស្ស។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីពិតប្រាកដនៃសត្វអូដ្ឋដែលចម្លងមេរោគវីរុស និងផ្លូវដែលវាចម្លងគឺមិនត្រូវបានគេដឹងពិតប្រាកដទេ។
- មេរោគហាក់ដូចជាមិនឆ្លងពីមនុស្សម្នាក់ទៅមុនុស្សម្នាក់ទៀតដោយងាយៗទេ ទាល់តែមានការប៉ះពាល់គ្នាដូចជានៅពេលប៉ះពាល់អ្នជំងឺដោយគ្មានការការពារ។

## រោគសញ្ញា

- វិសាលភាពវេជ្ជសាស្ត្រនៃការឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) រាប់បញ្ចូលទាំងការគ្មានរោគសញ្ញា ឬមានរោគសញ្ញាផ្លូវដង្ហើមស្រាល រហូតដល់ជំងឺផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ និងស្លាប់បាត់បង់ជីវិត។ ជំងឺរលាកសួត ជាធម្មតាត្រូវបានគេរកឃើញ ប៉ុន្តែមិនមែនរហូតទេ។ រោគសញ្ញាក្រពះពោះវៀន រាប់បញ្ចូលទាំងជំងឺរាកផងត្រូវបានរាយការណ៍។ ជំងឺធ្ងន់ធ្ងរអាចបណ្តាលឱ្យប្រព័ន្ធដកដង្ហើមមិនដំណើរការ ហើយត្រូវការដកដង្ហើមសិប្បនិម្មិត ព្រមទាំងត្រូវការអង្គភាពថែទាំឱ្យបានហ្មត់ចត់។ អ្នកជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) ៣៦%ត្រូវបានរាយការណ៍ថាបានស្លាប់បាត់បង់ជីវិត។ មេរោគវីរុស បណ្តាលឱ្យមានជំងឺធ្ងន់ធ្ងរដល់មនុស្សចាស់ មនុស្សមានប្រព័ន្ធការពារទន់ខ្សោយ និងមនុស្សមានជំងឺរ៉ាំរ៉ៃដូចជាមហារីក ជំងឺសួតរ៉ាំរ៉ៃ និងជំងឺទឹកនោមផ្អែម។

## ប្រភពនៃមេរោគវីរុស

- ជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) គឺជាមេរោគដែលចម្លងពីសត្វមកមនុស្ស។ ប្រភពដើមពិតប្រាកដនៃមេរោគវីរុស គឺមិនត្រូវបានគេដឹងឱ្យបានពិតប្រាកដទេ ប៉ុន្តែយោងតាមការវិភាគហ្សែនវីរុសខុសៗគ្នា វាត្រូវបានគេជឿជាក់ថាមានប្រភពដើមពីសត្វប្រចៀវ/ជ្រឹង បន្ទាប់មកឆ្លងមកសត្វអូដ្ឋកាលពីយូរលង់ណាស់មកហើយ។

## ការចម្លង

ពុំមានការឆ្លងពីមុស្សទៅមុនស្សទេះ ផ្លូវចម្លងពីសត្វទៅមនុស្សមិនត្រូវបានគេដឹងឱ្យបានពិតប្រាកដទេ ប៉ុន្តែសត្វអូដ្ឋទំនងជាប្រភពចម្លងធំជាងគេ ចំពោះជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) និងប្រភពចម្លងពីសត្វមកមនុស្ស។ មេរោគនៃជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) ដែលដូចគ្នាទៅនឹងមេរោគចម្លងមកមនុស្ស ត្រូវបានគេដាក់ឱ្យនៅដាច់ដោយឡែកពីសត្វអូដ្ឋនៅក្នុងប្រទេសជាច្រើន រាប់បញ្ចូលទាំងប្រទេសអេស៊ីប អូម៉ាន ហ្កាតា និងអារ៉ាប់ប៊ីសាអូឌីត។

ការចម្លងពីមនុស្សទៅមនុស្សៈ មេរោគវីរុសមិនងាយចម្លងពីមនុស្សទៅមនុស្សទេ ទាល់តែមានការប៉ះពាល់គ្នា ដូចជាផ្តល់ការថែទាំអ្នកជំងឺឆ្លងហើយគ្មានការការពារ។ មានករណីជាក្រុមក្នុងមណ្ឌលថែទាំសុខភាពដែលទំនងជាឆ្លងពីមនុស្សទៅមនុស្ស ជាពិសេសនៅពេលដែលការអនុវត្តន៍ការបង្ការ និងការត្រួតពិនិត្យជំងឺឆ្លងមិនបានគ្រប់គ្រាន់។ ដូច្នេះពុំមានការចម្លងមេរោគក្នុងសហគមន៍យូរអង្វែង ត្រូវបានគេចងក្រងទុកជាឯកសារទេ។

មេរោគឆ្លងទូទាំងឧបទ្វីបអារ៉ាប់ សំខាន់បំផុតនៅក្នុងប្រទេសអារ៉ាប៊ីសាអូឌីត ជាទីកន្លែងដែលករណីភាគច្រើនបានកើតឡើង (>៨៥%) ត្រូវបានរាយការណ៍តាំងពីឆ្នាំ២០១២។ មានករណីជាច្រើនទៀតត្រូវបានរាយការណ៍ខាងក្រៅមជ្ឈឹមបូព៌ា។ ភាគច្រើននៃការឆ្លងមេរោគទាំងនេះ ត្រូវបានគេជឿថា ទទួលបានមកពីមជ្ឈិមបូព៌ាបន្ទាប់មកចម្លងទៅក្រៅតំបន់។

ការផ្ទុះជំងឺដែលកំពុងតែកើតឡើងនៅក្នុងសាធារណរដ្ឋកូរេ គឺជាការផ្ទុះធំជាងគេបំផុតនៅក្រៅមជ្ឈិមបូព៌ា ហើយខណៈពេលដែលមានការព្រួយបារម្ភ មិនមានភស្តុតាងនៃការឆ្លងពីមនុស្សទៅមនុស្សទេ ក្នុងសារណរដ្ឋកូរេ។ ចំពោះករណីឆ្លងទៅក្រៅវិញ ពុំមានការឆ្លងលើកទីពីរត្រូវបានរាយការណ៍ក្នុងប្រទេសដែលមានករណីឆ្លងជំងឺទេ។

## ការបង្ការ និងការព្យាបាល

បច្ចុប្បន្នពុំមានថ្នាំបង្ការ ឬការព្យាបាលជាក់លាក់ទេ។ ការព្យាបាលគឺគ្រាន់តែគាំពារ និងផ្អែកលើស្ថានភាពជំងឺរបស់អ្នកជំងឺតែប៉ុណ្ណោះ។

ជាវិធានការប្រុងប្រៀបជើងការទុកជាមុន សម្រាប់នរណាម្នាក់ដែលទៅលេងកសិដ្ឋាន ផ្សារ ទ្រុងសត្វ និងកន្លែងដទៃទៀតដែលមានសត្វអូដ្ឋ និងសត្វដទៃទៀត គួរតែអនុវត្តវិធានការអនាម័យទូទៅ រាប់បញ្ចូលទាំងការលាងដៃជាប្រចាំមុន និងក្រោយប៉ះពាល់សត្វ និងគួរតែជៀសវាងការប៉ះពាល់សត្វឈឺ។

ការទទួលទានផលិតផលសាច់សត្វឆៅ ឯឬមិនបានចម្អិនឱ្យបានត្រឹមត្រូវ រាប់បញ្ចូលទាំងទឹកដោះគោ និងសាច់នាំឱ្យមានការឆ្លងជំងឺកម្រិតខ្ពស់ពីសរីរាង្គផ្សេងៗ ដែលអាចបណ្តាលឱ្យឆ្លងជំងឺមកមនុស្ស។ ផលិតផលសត្វដែលគេវេចខ្ចប់តាមរយៈការចម្អិន ឬការកំដៅសម្លាប់មេរោគ គឺមានសុវត្ថិភាពក្នុងការទទួលទាន ប៉ុន្តែគួរតែប្រុងប្រយ័ត្នដើម្បីជៀសវាងការឆ្លងពីចំណីអាហារឆៅ។ សាច់សត្វអូដ្ឋ និងទឹកដោះអូដ្ឋគឺជាផលិតផលដែលមានជីវជាតិ អាចត្រូវបានទទួលទានក្រោយពីការកំដៅសម្លាប់មេរោគ ចម្អិន និងតាមរយៈការសម្លាប់មេរោគដោយប្រើវិធីកម្តៅផ្សេងៗទៀត។

ទំរាំមានការយល់ដឹងច្រើនថែមទៀតអំពីជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) អ្នកជំងឺទឹកនោមផ្អែម តម្រងនោមមិនដំណើរការ ជំងឺសួតរ៉ាំរ៉ៃ និងអ្នកជំងឺខ្សោយប្រព័ន្ធការពារ គឺនៅតែត្រូវបានគេចាត់ទុកថាជាអ្នកមានហានិភ័យខ្ពស់ពីការឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ដែលជាជំងឺធ្ងន់ធ្ងរ។ មនុស្សទាំងនេះគួរតែជៀសវាងការប៉ះពាល់ជាមួយសត្វអូដ្ឋ ទទួលទានទឹកដោះអូដ្ឋ ឬទឹកនោមអូដ្ឋឆៅ ឬទទួលទានសាច់ដែលមិនបានចម្អិនត្រឹមត្រូវ។

## មណ្ឌលថែទាំសុខភាព

ការចម្លងមេរោគវីរុសបានកើតឡើងនៅក្នុងមណ្ឌលថែទាំសុខភាព ក្នុងប្រទេសជាច្រើន រាប់បញ្ចូលទាំងឆ្លងពីអ្នកជំងឺមកអ្នកថែទាំសុខភាព និងឆ្លងរវាងអ្នកជំងឺនៅក្នុងមណ្ឌលថែទាំសុខភាពនៅមុនពេលដែលជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ត្រូវបានគេរកឃើញ។ វាពុំមានមានភាពងាយស្រួលទេក្នុងការរកអ្នកជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ឱ្យបានឆាប់រហ័ស ឬដោយគ្មានការធ្វើតេស្ត ព្រោះរោគសញ្ញា និងលក្ខណៈវេជ្ជសាស្ត្រដទៃទៀតមិនមានភាពជាក់លាក់។

វិធានការបង្ការ និងត្រួតពិនិត្យការឆ្លងគឺជាអាយុជីវិត ដើម្បីបង្ការលទ្ធភាពនៃការឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ក្នុងមណ្ឌលថែទាំសុខភាព។ មណ្ឌលដែលផ្តល់ការថែទាំដល់អ្នកជំងឺ ហើយត្រូវបានគេសង្ស័យ ឬអះអាងថាបានឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ត្រូវមានវិធានការសមស្របដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគវីរុសពីអ្នកជំងឺដែលបានឆ្លង ទៅអ្នកជំងឺដទៃទៀត បុគ្គលិកថែទាំសុខភាព ឬភ្ញៀវ។ បុគ្គលិកថែទាំសុខភាពគួរត្រូវបានគេអប់រំ និងបណ្តុះបណ្តាលអំពីការបង្ការ និងការត្រួតពិនិត្យការឆ្លង ហើយគួរតែរំលឹកជំនាញទាំងនេះឱ្យបានទៀងទាត់។

## ការធ្វើដំណើរ

អង្គការសុខភាពពិភពលោក មិនផ្តល់អនុសាសន៍ឱ្យអនុវត្តការដាក់កំហិតដល់ការធ្វើដំណើរ ឬការប្រកមុខរបរទទួលទាន ឬការធ្វើតេស្តរកអ្នកជំងឺទាក់ទងទៅនឹងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-CoV) ទេ។

## ការឆ្លើយតបរបស់អង្គការសុខភាពពិភពលោក

អង្គការសុខភាពពិភពលោក កំពុងធ្វើការជាមួយវេជ្ជបណ្ឌិត និងអ្នកវិទ្យាសាស្ត្រ នៅក្នុងប្រទេសដែលបានឆ្លង និងជាអន្តរជាតិ ដើម្បីប្រមូល និងចែករំលែកភស្តុតាងវិទ្យាសាស្ត្រ ដើម្បីឱ្យមានការយល់ដឹងកាន់តែច្រើនថែមទៀតអំពីមេរោគវីរុស និងមូលហេតុរបស់វា និងធ្វើការសម្រេចចិត្តអំពីអាទិភាពនៃការឆ្លើយតបនៅពេលមាការផ្ទុះជំងឺ យុទ្ធសាស្ត្រព្យាបាល និងវិធីសាស្ត្រគ្រប់គ្រងផ្នែកវេជ្ជសាស្ត្រ។ អង្គការក៏កំពុងធ្វើការជាមួយប្រទេសនានា ដើម្បីបង្កើតយុទ្ធសាស្ត្របង្ការសុខភាពសាធារណៈ ដើម្បីប្រយុទ្ធជាមួយមេរោគវីរុស។

រួមគ្នាជាមួយប្រទេសដែលបានឆ្លងជំងឺ និងដៃគូបច្ចេកទេសអន្តរជាតិ និងបណ្តាញនានា អង្គការសុខភាពពិភពលោកកំពុងសម្របសម្រួលការឆ្លើយតបសុខភាពពិភពលោក ជាមួយជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) រាប់បញ្ចូលទាំងៈ ការផ្តល់ព័ត៌មានទាន់ហេតុការណ៍ អនុវត្តការប៉ាន់ប្រមាណ និងការស៊ើបអង្កេតដោយមានការចូលរួមជាមួយអាជ្ញាធរជាតិនានា ការកោះប្រជុំជាលក្ខណៈវិទ្យាសាស្ត្រ និងបង្កើតគោលការណ៍ណែនាំ និងបណ្តុះបណ្តាលដល់អាជ្ញាធរសុខាភិបាល និងទីភ្នាក់ងារបច្ចេកទេសស្តីពីអនុសាសន៍តាមដានបណ្តោះអាសន្ន ករណីធ្វើតេស្តមន្ទីរពិសោធន៍ ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ និងការគ្រប់គ្រងផ្នែកវេជ្ជសាស្ត្រ។

អគ្គនាយកបានកោះប្រជុំគណៈកម្មាធិការគ្រាអាសន្ន ក្រោមនិយ័តកម្មសុខភាពអន្តរជាតិ (២០០៥) ដើម្បីផ្តល់យោបល់ដល់លោកស្រីថាតើព្រឹត្តិការណ៍នេះ ស្របតាមការព្រួយបារម្ភជាអន្តរជាតិអំពីគ្រាអាសន្នសុខភាពសាធារណៈ (PHEIC) ដែរឬទេ និងថាតើវិធានការសុខភាពសាធារណៈអ្វីខ្លះដែលត្រូវអនុវត្ត។ គណៈកម្មាធិការនេះបានជួបប្រជុំច្រើនលើករួចមកហើយ ចាប់តាំងពីជំងឺត្រូវបានរកឃើញ។ អង្គការសុខភាពពិភពលោកលើកទឹកចិត្តឱ្យរដ្ឋជាសមាជិកទាំងអស់ ធ្វើឱ្យបានប្រសើរឡើងនូវការតាមដានជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SAR) និងត្រួតពិនិត្យដោយយកចិត្តទុកដាក់បំផុតលើលក្ខណៈមិនធម្មតានៃជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ (SAR) ឬជំងឺករណីជំងឺរលាកសួត។

ប្រទេសទាំងឡាយដែលមាន ឬមិនមានករណីជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS) ត្រូវបានរាយការណ៍ក៏ដោយ គួរតែរក្សាការតាមដានដោយប្រុងប្រយ័ត្នបំផុត ជាពិសេសប្រទេសដែលមានចំនួនអ្នកធ្វើដំណើរ ឬកម្មករចំណាកស្រុកច្រើន ដែលត្រឡប់មកពីមជ្ឈិមបូព៌ាវិញ។ ការតាមដានគួរតែបន្ត ដើម្បីធ្វើឱ្យប្រសើរឡើងក្នុងប្រទេសទាំងនេះ អនុលោមតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក និងស្របតាមនីតិវិធីបង្ការ និងត្រួតពិនិត្យនៅតាមមណ្ឌលថែទាំសុខភាពនានា។ អង្គការសុខភាពពិភពលោកបន្តស្នើសុំឱ្យរដ្ឋជាសមាជិកទាំងអស់រាយការណ៍ជូនអង្គការសុខភាពពិភពលោក ចំពោះករណីដែលបានអះអាងថាមាន និងករណីដែលទំនងជាមាន ការឆ្លងជំងឺផ្លូវដង្ហើមមជ្ឈិមបូព៌ា (MERS-Cov) ជាមួយនឹងព័ត៌មានអំពីការប្រឈម ការធ្វើតេស្ត និងវិធានការវេជ្ជសាស្ត្រ ដើម្បីជម្រាបជូនអំពីការបត្រៀមបម្រុង និងឆ្លើយតបជាអន្តរជាតិឱ្យមានប្រសិទ្ធិភាពបំផុត៕